CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១១ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបានបើកដំណើរការប្រព័ន្ធ SafeBiz ដែលនឹងផ្តល់អាជីវកម្មនូវវិញ្ញាបនប័ត្រដែលធ្វើដោយខ្លួនឯងបញ្ជាក់ពីការអនុវត្តវិធានការណ៍រក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នា

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះទីក្រុងឡុងប៊ិចបានបើកដំណើរការ SafeBiz ដែលជាប្រព័ន្ធអ៊ីនធឺណិតដែលអនុញ្ញាតឱ្យអាជីវកម្មដែលអាចបើកដោយយោងតាម "បទបញ្ជារក្សាសុវត្ថិភាពដោយនៅផ្ទះ" បញ្ជាក់ដោយខ្លួនឯងថាពួកគាត់ប្តេជ្ញាថានឹងបើកអាជីវកម្មរបស់ពួកគាត់ឡើងវិញដោយសុវត្ថិភាព។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ការធានានូវវិធានការណ៍នានាដើម្បីបើកអាជីវកម្មដោយសុវត្ថិភាពនៅទូទាំងទីក្រុងរបស់យើងគឺចាំបាច់ដើម្បីទប់ស្កាត់ការរាលដាលនៃ COVID-19។ ការបន្តបើកទីក្រុងរបស់យើងឡើងវិញនៅតែជាអាទិភាពកំពូល។ ការបើកដោយសុវត្ថិភាពដែលយោងតាមការគាំទ្រពីទិន្នន័យក្នុងស្រុកនឹងបន្តដឹកនាំដំណើរការរបស់យើង។

SafeBiz ណែនាំម្ចាស់អាជីវកម្មតាមរយៈបញ្ជីត្រួតពិនិត្យនៃវិធានការសុវត្ថិភាពដែលតំរូវដោយបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ" ដើម្បីការពារការរាលដាលនៃ COVID-19។ បទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ" ឧបសម្ព័ន្ធកះពិធីសារអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នារួមមានវិធានការណ៍ដើម្បី

ការពារសុខភាពបុគ្គលិក រក្សាហ្វូងមនុស្សពីការប្រមូលផ្តុំ រក្សាមនុស្សឱ្យនៅដាច់ពីគ្នាយ៉ាងតិច ៦ ហ្វីត និងការពារការទាក់ទងដែលមិនចាំបាច់ និងបង្កើនវិធានការណ៍អនាម័យដើម្បីបង្កើតបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់អតិថិជន។ អាជីវកម្មនីមួយៗត្រូវតែអនុវត្តរាល់វិធានការណ៍ដែលអាចអនុវត្តបានឬត្រូវត្រៀមដើម្បីពន្យល់ថាហេតុអ្វីវិធានការដែលមិនត្រូវបានអនុវត្តមិនអាចអនុវត្តបានចំពោះអាជីវកម្មនោះ។ ប្រសិនបើសំណួរទាំងអស់ត្រូវបានឆ្លើយយ៉ាងត្រឹមត្រូវនោះវិញ្ញាបនប័ត្រនឹងត្រូវបានបង្កើតភ្លាមបន្ទាប់ពីខាងអាជីវកម្មបានបញ្ចប់ការវាយតម្លៃខ្លួនឯងដែលនឹងចេញទម្រង់ជាលិខិតមួយដែលអាចបោះពុម្ពបានដោយអាជីវកម្មដើម្បីបិទផ្សាយនៅកន្លែងដែលអាចមើលឃើញរួមជាមួយការបិទផ្សាយពិធីសារអនុវត្តការរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នា។

បុគ្គលិកអនុវត្តន៍ច្បាប់កូដនៃឡុងប៊ិចនឹងយូរៗម្តងពិនិត្យសាឡើងវិញនូវរាល់វិញ្ញាបនប័ត្រដើម្បីធានាថាវាមានសុពលភាពហើយនឹងប្រើប្រាស់មូលដ្ឋានទិន្នន័យដើម្បីធ្វើការត្រួតពិនិត្យកន្លែងអាជីវកម្មដើម្បីបញ្ជាក់ពីការអនុលោម។

ពលរដ្ឋអាចរាយការណ៍អំពីការបំពាននិងអាជីវកម្មដែលមិនគោរពវិធានការណ៍សុវត្ថិភាពដោយទូរស័ព្ទទៅលេខ 562.570.2633 ឬអ៊ីម៉ែលទៅកាន់ CETaskForce@LongBeach.gov។

SafeBiz គឺជាកិច្ចប្រឹងប្រែងមួយក្នុងចំណោមកិច្ចប្រឹងប្រែងជាច្រើនរបស់ទីក្រុងដើម្បីដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចដោយសារតែ COVID-19 និងបើកដំណើរការទីក្រុងឡើងវិញដោយសុវត្ថិភាព។ សកម្មភាពផ្សេងទៀតរួមមានការបង្កើតមូលនិធិសង្គ្រោះគ្រោះមហន្តរាយឡុងប៊ិច កញ្ចប់ជំនួយសេដ្ឋកិច្ចដ៏ទូលំទូលាយមួយដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាក្រុងកាលពីថ្ងៃទី ១៤ ខែមេសា ការចាប់ផ្តើមនៃកម្មវិធី Work Long Beach នៅ Pacific Gateway ការស្ទង់មតិសហគមន៍ ReopenLB និងការបង្កើតក្រុមប្រឹក្សាស្តារសេដ្ឋកិច្ច។ ទីក្រុងឡុងប៊ិចក៏បានបង្កើតគេហទំព័រមួយដែលមានធនធានសម្រាប់អាជីវកម្មនិងអ្នកធ្វើការក៏ដូចជាបណ្តាញទូរស័ព្ទបន្ទាន់សម្រាប់ម្ចាស់អាជីវកម្មនិងនិយោជិកនៅលេខ 562.570.4BIZ (4249) ដែលមានបុគ្គលិកចាំលើកចាប់ពីម៉ោង ៨ ព្រឹកដល់ម៉ោង ៥ ល្ងាចពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។

សម្រាប់ព័ត៌មានថ្មីៗអំពីជម្ងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្ត ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###